ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ១០ លេខ ៨

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

កសវ



Work Activities

ប្រចាំខែសីហា ឆ្នាំ២០១៧



# មាតិកា


| ល.រ បរិយាយ | លេខទំព័រ |
|---|---|
| I- កិច្ចប្រជុំជំនាញបច្ចេកទេស | |
| ១- សេចក្តីព្រាងសារាចរស្តីពីការរៀបចំទិវាមនុស្សចាស់កម្ពុជានិងទិវាមនុស្សអន្តរជាតិ ០១ តុលា ឆ្នាំ២០១៧ | ១-២ |
| ២- សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ | ៣ |
| II- សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត( ក្រុម RIA ) | |
| - វគ្គបណ្តុះបណ្តាលអំពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា | ៤-៧ |
| III- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែកក្កដា ឆ្នាំ២០១៧ | ៨-១៥ |
| IV- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១៧ | ១៦-១៩ |

# ១- សេចក្តីព្រាងសារាចរស្តីពី

## ការរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សអន្តរជាតិ ០១ តុលា ឆ្នាំ២០១៧

កាលពីថ្ងៃទី២ ខែសីហា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុក ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងសារាចរស្តីពីការរៀបចំទិវាមនុស្សចាស់កម្ពុជានិងទិវាមនុស្សអន្តរជាតិ ០១ តុលា ឆ្នាំ២០១៧** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។



ដោយយោងតាមអនុក្រឹត្យលេខ ១៥៨ អនក្រ. ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំសារាចរស្តីពីការរៀបចំទិវាមនុស្សចាស់កម្ពុជានិងទិវាមនុស្សអន្តរជាតិ ០១ តុលា ឆ្នាំ២០១៧ ដើម្បីគាំទ្រមនុស្សចាស់នៅកម្ពុជា។

ទីវាមនុស្សចាស់កម្ពុជានិងទិវាមនុស្សចាស់អន្តរជាតិថ្ងៃទី១ ខែតុលា ត្រូវបានរៀបចំស្របតាមគោលនយោបាយជាតិសម្រាប់មនុស្សចាស់នៃព្រះរាជាណាចក្រកម្ពុជា និងសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ។ ការប្រារព្ធទិវានេះមានគោលបំណងលើកកម្ពស់កិច្ចគាំពារដ៏មានប្រសិទ្ធភាពសំដៅលើកស្ទួយសុខុមាលភាពរបស់មនុស្សចាស់ឲ្យកាន់តែប្រសើរឡើង ហើយទិវានេះក៏បង្ហាញឲ្យឃើញពីតួនាទីដ៏សំខាន់របស់មនុស្សចាស់បុព្វការីជនដែលបានបង្កើតធនធានដ៏មានសារប្រយោជន៍ ព្រមទាំងផ្តល់នូវចំណេះដឹង ចំណេះធ្វើ និងបទពិសោធយ៉ាងច្រើនឥតគណនាសម្រាប់មនុស្សជំនាន់ក្រោយ។ ក្នុងគោលបំណងយកចិត្តទុកដាក់ខ្ពស់ចំពោះមនុស្សចាស់កម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ ដើម្បីអនុវត្តនូវតួនាទីនិងភារកិច្ចដែលមានជាអាទិ៍ រៀបចំគោលនយោបាយជាតិដើម្បីលើកស្ទួយសុខុមាលភាពរបស់មនុស្សចាស់ និងរៀបចំទីវាមនុស្សចាស់នៃព្រះរាជាណាចក្រកម្ពុជា ដោយកំណត់យកថ្ងៃទី១ ខែតុលា ជារៀងរាល់ឆ្នាំ រួមជាមួយទិវាមនុស្សចាស់អន្តរជាតិ។

រាជរដ្ឋាភិបាលចាត់ទុកទិវាមនុស្សចាស់កម្ពុជានិងទិវាមនុស្សអន្តរជាតិជាទិវាបុណ្យរលឹកគុណូបការៈរបស់មនុស្សចាស់កម្ពុជា បុព្វការីជន ជីដូនជីតា អ៊ុំ ពូ មីង ដែលបានកសាងនិងមន្សល់ទុកនូវកេរមរតកដ៏ថ្លៃថ្លាសម្រាប់កូនចៅជំនាន់ក្រោយៗទៀត[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ៕




(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសារាចរស្តីពីការរៀបចំទិវាមនុស្សចាស់កម្ពុជានិងទិវាមនុស្សអន្តរជាតិ ០១ តុលា ឆ្នាំ២០១៧។

# ២- សេចក្តីព្រាងអនុក្រឹត្យស្តីពី

## ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍

កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **អ៊ុំ ម៉ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាង អគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងអប់រំ យុវជន និងកីឡា។

អនុវត្តតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ស្តីពី ការអប់រំ និងសេចក្តីប្រកាសទីក្រុង Incheon វិស័យអប់រំឆ្នាំ២០៣០ ក្រសួងអប់រំ យុវជន និងកីឡា បាន រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ សំដៅផ្តល់ឱកាសឲ្យកុមារដែលមាន អាយុចាប់ពីបីឆ្នាំ ដល់ក្រោមប្រាំមួយឆ្នាំ ទទួលបានសេវាអប់រំ ប្រកបដោយសមធម៌និងបរិយាបន្ន នៅតាម មត្តេយ្យសិក្សាសហគមន៍ដែលបង្កើតឡើងដោយរដ្ឋបាលឃុំ សង្កាត់ និងទទួលបានការគាំទ្រផ្នែកបច្ចេកទេស និងសម្ភារៈពីក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍស្របតាមកម្មវិធីកំណែទម្រង់វិស័យអប់រំ ដែល បានដាក់ចេញនូវក្នុងនីតិកាលទី៥ នៃរដ្ឋសភា។ ការធានាដំណើរការ និងសកម្មភាពរបស់មត្តេយ្យសិក្សា សហគមន៍ គឺជាយន្តការមួយក្នុងចំណោមយន្តការគន្លឹះនានា សម្រាប់ជំរុញឲ្យកុមារតូចទទួលបានសេវាអប់រំ ប្រកបដោយបរិយាបន្ន សមធម៌ និងជាការរួមចំណែកដ៏សំខាន់ក្នុងការអនុវត្តគោលនយោបាយជាតិគាំពារ និងអភិវឌ្ឍកុមារតូច ព្រមទាំងជាយន្តការមួយសមស្របសម្រាប់ឈានឆ្ពោះទៅរកការបណ្តុះបណ្តាលធន ធានមនុស្សឲ្យក្លាយជាមូលធនមនុស្ស ដើម្បីសម្រេចចក្ខុវិស័យឆ្នាំ២០៣០ ដែលរាជរដ្ឋាភិបាលចង់ប្រែក្លាយ ប្រទេសកម្ពុជា ជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ និងក្លាយជាប្រទេសអភិវឌ្ឍនៅក្នុងឆ្នាំ២០៥០ខាងមុខ និងសម្រេចបានស្របតាមគោលដៅនៃសេចក្តីប្រកាសទីក្រុង Incheon វិស័យអប់រំឆ្នាំ២០៣០ ដែលបាន កំណត់ថា "ត្រឹមឆ្នាំ២០៣០ ធានាថាកុមារី និងកុមារាទាំងអស់ទទួលបានការអប់រំកម្រិតមត្តេយ្យ ការថែរក្សា និងការអភិវឌ្ឍកុមារតូចប្រកបដោយគុណភាព ដូច្នេះពួកគេត្រៀមខ្លួនជាស្រេចសម្រាប់ការអប់រំកម្រិតបឋម សិក្សា[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរ ក្រសួងនាពេលខាងមុខ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍។

# វគ្គបណ្តុះបណ្តាលអំពីវិធីសាស្ត្រវាយតម្លៃ លើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

## (Regulatory Impact Assessment Implementation)

## នៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា




នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី បានបើកវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (Regulatory Impact Assessment Methodology) ជូនដល់មន្ត្រីនិងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួនប្រមាណ ៧0រូប ចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ នៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ឯកឧត្តម **ម៉ិច សុខា** អគ្គលេខាធិការរងECOSOCC និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត និងឯកឧត្តម **អេង រត្នមុន្នី** អគ្គលេខាធិការរង ECOSOCC និងជាប្រធានផ្នែកបណ្តុះបណ្តាលនៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត វាគ្មិនក្នុងវគ្គបណ្តុះបណ្តាលនេះ។

ជាកិច្ចចាប់ផ្ដើមវគ្គបណ្ដុះបណ្ដាល ឯកឧត្ដម អគ្គលេខាធិការ ព្រឹទ្ធសភា បានមតិស្វាគមន៍ ថា "ជាបឋម ខ្ញុំមានសេចក្ដីសោមនស្សរីករាយ ចូលរួមក្នុងកម្មវិធីបណ្ដុះបណ្ដាលនាពេលនេះ ស្ដីពីធាតុទាំង៧ នៃវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ហៅកាត់ថាRIA និងសូមស្វាគមន៍ចំពោះ វត្តមាន ឯកឧត្ដម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ដែលបានអញ្ជើញចូលរួមវគ្គបណ្ដុះ បណ្ដាលនាពេលនេះ។

ខ្ញុំសូមសម្ដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ និងស្វាគមន៍យ៉ាងកក់ក្ដៅចំពោះក្រុមការងារ RIA ដែល ដឹកនាំដោយឯកឧត្ដម **ម៉ិច សុខា** អគ្គលេខាធិការរង ECOSOCC និងជាអនុប្រធាន អចិន្ត្រៃយ៍នៃក្រុម ប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ដែលឯកឧត្ដម និងក្រុមការងារបានមកធ្វើការផ្សព្វផ្សាយអំពីវិធីសាស្ត្រវាយ តម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តដល់មន្ត្រី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជាពិសេសមន្ត្រី ជំនាញច្បាប់ និងអ្នកពាក់ព័ន្ធទៅលើការងារស្រាវជ្រាវច្បាប់ ដែលចាប់ដំណើរការក្នុងរយៈពេលពីរថ្ងៃ គឺពីថ្ងៃទី ២៥ - ២៦ ខែកក្កដា ឆ្នាំ២០១៧។

កម្មវិធីRIAនេះ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការធ្វើកំណែទម្រង់ដ៏ស៊ី ជម្រៅ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមឲ្យកាន់តែប្រសើរឡើង ដូចមានបញ្ជាក់ ច្បាស់នៅក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

អង្គនីតិប្បញ្ញត្តិព្រឹទ្ធសភា បានយកចិត្តទុកដាក់ខ្លាំងណាស់ក្នុងការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិ យុត្តឲ្យប្រសើរឡើង និងមានប្រសិទ្ធិភាពខ្ពស់។





វិធីសាស្ត្រRIAនេះ គឺជាឧបករណ៍ដ៏ល្អមួយក្នុងដំណើរការរៀបចំសំណើលិខិតបទដ្ឋានគតិយុត្តឲ្យមានប្រសិទ្ធិភាព និងប្រសើរឡើង។ ការអនុវត្តRIAនឹងផ្តល់នូវផលចំណេញជាច្រើន ដែលប្រទេសអភិវឌ្ឍទទួលស្គាល់យ៉ាងទូលំទូលាយអស់រយៈជាច្រើនទសវត្សមកហើយ ដូចជា លិខិតបទដ្ឋានមានគុណភាពខ្ពស់ ដែលនាំឲ្យអភិបាលកិច្ចល្អ ជំរុញកំណើនសេដ្ឋកិច្ច បង្កើនតម្លាភាព គណនេយ្យភាព និងពិសេសទៅទៀតគឺជំនឿទុកចិត្តពីសាធារណជន និងធុរជន ជួយកាត់បន្ថយបន្ទុកការិយាធិបតេយ្យ ឬវិសាលភាព ភាពជាន់គ្នា ជួយកាត់បន្ថយបន្ទុកចំណាយរបស់រដ្ឋបាលលើការអនុវត្ត និងបន្ទុកចំណាយប្រតិបត្តិការរបស់ធុរកិច្ចជាដើម។

ម្យ៉ាងទៀត ការយកចិត្តទុកដាក់អំពីបន្ទុកចំណាយ និងផលចំណេញនៃសំណើបញ្ញត្តិកម្ម ក៏ជាទិសដៅចំបងរបស់RIA ដែលនាំឲ្យអភិបាលកិច្ចល្អ និងការសម្រេចលើបញ្ញត្តិកម្មកាន់តែមានតម្លាភាព។ ការគណនាបន្ទុកចំណាយ និងផលចំណេញនឹងអាចជួយកំណត់បាននូវជម្រើសចំណាយតិច ដែលសម្រេចគោលបំណងបញ្ញត្តិបានដូចគ្នា។

ការងារRIA មិនមែនជាការងារនីត្យានុកូលនោះទេ។ ការអនុវត្តRIAនេះមិនប៉ះពាល់ ឬជាន់សមត្ថកិច្ច និងភារកិច្ចជាមួយគោលការណ៍ណែនាំស្តីពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនោះទេ ព្រោះមួយនិយាយអំពីទម្រង់នៃការតាក់តែង រីឯមួយទៀតគឺការវិភាគអំពីផលប៉ះពាល់តែប៉ុណ្ណោះ។ ការងារRIA គឺវាយតម្លៃបញ្ញត្តិកម្មណាដែលមានផលប៉ះពាល់ ដើម្បីជៀសវាង ឬកាត់បន្ថយជាអតិបរិមានូវផលអវិជ្ជមាន ដល់ធុរកិច្ច សង្គម និងបរិស្ថាន និងផ្តល់ព័ត៌មានឲ្យបានគ្រប់ជ្រុងជ្រោយជូនថ្នាក់ដឹកនាំដើម្បីងាយស្រួលក្នុងការសម្រេច ពីព្រោះប្រទេសយើងគ្មាន sunset clause ដូចប្រទេសខ្លះនោះទេ ដែលមានបញ្ញត្តិកំណត់សុពលភាពនៃបញ្ញត្តិកម្ម ដូចជា ៦ឆ្នាំអស់សុពលភាពហើយ ហើយបើចង់បន្តត្រូវវាយតម្លៃឡើងវិញ។

សូមជម្រាបថា អាស៊ានកំពុងយកចិត្តទុកដាក់ខ្លាំងណាស់ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តឲ្យមានប្រសិទ្ធិភាព និងប្រសើរឡើង ដើម្បីលើកស្ទួយឧស្សាហកម្មធុនតូច និងមធ្យមនៅក្នុងតំបន់ ទៅតាមគោលការណ៍ប្រតិបត្តិល្អលិខិតបទដ្ឋានគតិយុត្ត Good Regulation Practice ដែលយកRIAជាយន្តការ។ ប្រទេសសមាជិកអាស៊ានមួយចំនួន កំពុងអនុវត្តRIAជាផ្លូវការ ដូចជាវៀតណាម ឡាវ ដោយបានចែងនៅក្នុងច្បាប់ ឬកំពុងអនុវត្តសាកល្បង ដូចជាហ្វីលីពិន និងម៉ាឡេស៊ីជាដើម។

នៅអូស្ត្រាលី និងចក្រភពអង់គ្លេស គេប្រើប្រាស់RIAជាឧបករណ៍សម្រាប់កាត់បន្ថយបន្ទុកការិយាធិបតេយ្យ និងកាត់បន្ថយបញ្ញត្តិកម្មទៀតផង តាមរយៈវិធានបញ្ចូលបញ្ញត្តិកម្មមួយ ត្រូវលុបបញ្ញត្តិកម្មមួយ (១ចូល-១ចេញ) ឬបញ្ចូលបញ្ញត្តិកម្មមួយ ត្រូវលុបបញ្ញត្តិកម្មពីរ (១ចូល-២ចេញ)។

ការអនុវត្តវិធីសាស្ត្រRIA ជាទ្រឹស្តីគឺងាយស្រួលយល់ណាស់ តែការអនុវត្តជាក់ស្តែងនឹងមានការប្រឈមជាច្រើន ដូចជាការធ្វើការពិគ្រោះយោបល់ឲ្យមានគុណភាព និងប្រសិទ្ធិភាព ឬការគណនាបន្ទុកចំណាយ និងផលចំណេញនៃសំណើបញ្ញត្តិកម្មជាបរិមាណ ឬការធ្វើរបាយការណ៍RIAជូនថ្នាក់ដឹកនាំជាដើម។ តែបើការប្រតិបត្តិRIAឲ្យបានជាប់លាប់ នោះនឹងទៅជាទម្លាប់ Good Regulation Practice ដែលនាំឲ្យមានពិសោធន៍កាន់តែច្រើន ហើយការគណនាបន្ទុកចំណាយ និងផលចំណេញ និងការធ្វើរបាយការណ៍RIA ក៏កាន់តែមានគុណភាពឡើង។

ជាពិសេសទៅទៀត ការប្រតិបត្តិRIAជាប់លាប់ អាចបង្កើតបាននូវទិន្នន័យអំពីបន្ទុកចំណាយរដ្ឋបាលជាមធ្យមមួយសម្រាប់ប្រទេសយើង ដែលនឹងមានប្រយោជន៍ខ្លាំងណាស់ដល់ក្រុមការងារ RIA ក្នុងការងារជួយកាត់បន្ថយបន្ទុកការិយាធិបតេយ្យ និងកែលម្អបញ្ញត្តិកម្មទៀតផង។ នៅប្រទេសគេៗធ្វើបាន ដូចជាចំណាយពេលវេលាបំពេញបែបបទតម្រូវតាមបញ្ញត្តិកម្មអស់មួយម៉ោង អាចគិតជាសាច់ប្រាក់អស់ប៉ុន្មានដែលអាចឲ្យប្រទេសគេដាក់ទិសដៅកាត់បន្ថយបន្ទុកការិយាធិបតេយ្យប៉ុន្មានលានក្នុង១ឆ្នាំ ហើយគេក៏អាចវាយតម្លៃការអនុវត្ត ផែនការនោះបានទៀតផង ដោយសារមានរង្វាស់។

សូមជម្រាបថា ការអនុវត្តRIA ពីប្រទេសមួយទៅប្រទេសមួយ មានទម្រង់ខុសៗគ្នា។ ការអនុវត្តRIA នៅកម្ពុជា មានទម្រង់ប្រហាក់ប្រហែលដែលគេអនុវត្តនៅអូស្ត្រាលី តែមិនតឹងតែងដូចគេនោះទេ ដោយយើងនៅក្នុងដំណាក់កាលនៃការកសាងធនធានមនុស្សនៅឡើយ។ តែRIAទាមទារឲ្យក្រសួងអនុវត្តគោលការណ៍ Good Regulation Practice និងវាយតម្លៃសំណើបញ្ញត្តិកម្មណាដែលមានផលប៉ះពាល់ដល់ធុរកិច្ច សង្គម និងបរិស្ថាន។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ឯកឧត្តមជាវាគ្មិន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមប្រកាសបើកកម្មវិធីបណ្តុះបណ្តាលស្តីពី ធាតុទាំងប្រាំពីរនៃពិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយត្តិចាប់ពីពេលនេះតទៅ៕"

# III- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកក្កដា ឆ្នាំ២០១៧



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា **ប្រចាំខែកក្កដា ឆ្នាំ២០១៧**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គ-លេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែកក្កដា ឆ្នាំ២០១៧សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៣%ធៀបនឹងខែមុន និងកើនឡើង២,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៦,៥% | ប្រេងម៉ាស៊ូត: | +៦,៩% |
| ការដឹកជញ្ជូន: | +២,៩% | ប្រេងសាំង: | +៦,៣% |
| ម្ហូបអាហារ: | +២,៧% | ត្រីស្រស់: | +៥,៤% |
| សំលៀកបំពាក់ និងស្បែកជើង: | +២,៥% | បន្លែ: | +៣,២% |
| ការកំសាន្ត និងវប្បធម៌: | +២% | សាច់គោ: | +២% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +១,៥% | សាច់មាន់: | +១,៩% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +១,៤% | សាច់ជ្រូក: | +១,២% |
| សុខាភិបាល: | -៩,៨% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៥–២០១៧

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា P | កញ្ញា P | តុលា P | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៧ | ដូចគ្នាឆ្នាំមុន | ៤,៤% | ៤,០% | ៤,២% | ៣,២% | ២,៥% | ២,៣% | ២,៣% | ២,៣% | ២,៣% | ០,៨% | | | |
| | មុន | ០,៣% | ០,១% | ០,០% | ០,៤% | -០,២% | ០,១% | ០,៣% | ០,១% | ០,៣% | -១,១% | | | |
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣% |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៥% | ០,២% | ០,៣% | ០,២% | ០,៣% | ០,៤% | ០ | ០,៤% | |
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |
| | មុន | -០,៤% | ១,២% | ០,១% | ០,៧% | ០,១% | ០,២% | ០,៦% | ០,៣% | ០,២% | ០% | -០,២% | ០,២% | |

P: តួលេខខែសីហា កញ្ញា និងតុលាឆ្នាំ២០១៧ ជាតួលេខព្យាករ (តាមវិធីសាស្រ្ត DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរបស់ខ្លួន។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | កក្កដា ២០១៧ | មិថុនា ២០១៧ | កក្កដា ២០១៦ | *ប្រភេទ* | កក្កដា ២០១៧ | មិថុនា ២០១៧ | កក្កដា ២០១៦ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៩៨៛/១$ | ៤០៨៦៛/១$ | ៤០៩៧៛/១$ | **បាត/ដុល្លារ** | ៣៣,៣៤បាត/១$ | ៣៣,៩៩បាត/១$ | ៣៤,៨៥បាត/១$ |
| **៛/បាត** | ១២៣៛/១បាត | ១២០៛/១បាត | ១១៨៛/១បាត | **ដុង/ដុល្លារ** | ២២៧១១ដុង១$ | ២២៧៣០ដុង១$ | ២២២៧៨ដុង/១$ |
| **៛/ដុង** | ០,១៨០៛/១ដុង | ០,១៨០៛/១ដុង | ០,១៨៤៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់ធនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែកក្កដា ឆ្នាំ ២០១៧ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១២១១,៧ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៣០២,៩លានដុល្លារ (*មធ្យមប្រចាំខែ១០៦% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន១១៤៧,៤ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ២៨៦,៨៥លានដុល្លារ (*មធ្យមប្រចាំខែ ១០៥% នៃផែនការ*) និងចំណូលមូលធនមានចំនួន៦៤,៣ ប៊ីលានរៀល (*មធ្យមប្រចាំខែ ២៧០% នៃផែនការ*) (តាមតួលេខ ធនាគារជាតិ)។

➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិថយចុះ០,៥% ប៉ុន្តែ កើនឡើង២,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៥–២០១៧ (ប៊ីលានរៀល)




➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១០៤៨,៨ប៊ីលានរៀល កើនឡើង៤,៣% ធៀបនឹងខែមុន និងកើនឡើង៦,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ ធនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន៩៨,៦ប៊ីលានរៀល ថយចុះ៤៤,៧%ធៀបនឹងខែមុន និងថយចុះ ៣៨,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ ធនាគារជាតិ)។

តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

| ចំណូលសារពើពន្ធ (ក្នុងរង្វង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ចំណូលមិនមែនសារពើពន្ធ (តាមតួលេខ រតនាគារជាតិ) (ក្នុងរង្វង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: +០,៣% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+៦,៩%) | ➢កាស៊ីណូ : -៥៥,៤% | (-៣២,៤%) |
| | | ➢អាជ្ញាបណ្ណក្នុងស្រុក : +១១៦,៥% | (+៤៨,០%) |
| ➢ ចំណូលពន្ធដារ: +១៣,២% (អគ្គនាយកដ្ឋានពន្ធដារ) | (+១២,១%) | ➢ នេសាទ: -៩៤,៨% | (-៧២,៧%) |
| | | ➢សម្បទានរ៉ែ: -៤៧% | (-៧២,៥%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: +១៣៦,៣% | (+១៤៩,០%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: -១០០% | (-៩៩,៩%) |
| | | ➢អាករស្ពានទូក(លិខិតឆ្លងដែននិងទិដ្ឋាការ): -២៤,០% | (+៣៥,៩%) |
| | | ➢ការត្រួតពិនិត្យគុណភាពផលិតផល: -៨,៣% | (-៩០,៦%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ១៤៤៨,៧ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៣៦២,១៨លានដុល្លារ (*មធ្យមប្រចាំខែ ៧៧% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ១២៦៩,៩ប៊ីលានរៀល (*មធ្យមប្រចាំខែ ៨៣% នៃផែនការ*) និងចំណាយមូលធនមានចំនួន ១៧៨,៨ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិកើនឡើង២៣,៩% ធៀបនឹងខែមុននិងកើនឡើង៣៤,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង២៤,៥% ធៀបនឹងខែមុននិងកើនឡើង៥៣,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានឱនភាពចំនួន ២៣៧ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៥៩,២៥លានដុល្លារ (តួលេខរតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៥–២០១៧
(ប៊ីលានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកក្កដា ឆ្នាំ២០១៧មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន ៦៧០២០ប៊ីលានរៀល កើនឡើង២,៧%ធៀបនឹងខែមុន និងកើនឡើង ២០,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង $M_2$** ក្នុងខែនេះ ជារួម បណ្តាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ៥,៥% ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ៥% និងប្រាក់បញ្ញើជារូបិយបណ្ណ ២,៣%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែកក្កដា ឆ្នាំ២០១៧



➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៦,៣% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៣,៧% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៧

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៦,៧% | ១៦,៦% | ១៥,៥% | ១៥,៣% | ១៥,៧% | ១៦,០% | ១៦,៣% | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៣% | ១១,៤% | ១១,៣% | ១១,៣% | ១១,២% | ១១,១% | ១១,៤% | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែកក្កដា២០១៧: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន៨០៥២លានដុល្លារ កើនឡើង៣,៦%ធៀបនឹងខែមុន និងកើនឡើង៣៨,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** : ក្នុងខែនេះមានចំនួន២៤៨៩៤ប៊ីលានរៀលកើនឡើង ៤,៤%ធៀបនឹងខែមុន និងកើនឡើង៣៦,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *កក្កដា ២០១៧* | *មិថុនា២០១៧* | *កក្កដា ២០១៦* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល) | ៦៣៤៨០ | ៦២៧៦៩ | ៥៥៣៤៩ |
| ក្នុងនោះ ជារៀល | | ១០៨៣ | ៧៨៦ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ១៤៦៦៣ | ១១៤៤៨ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,០៥% | ៦,០៣% | ៦,៨១% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៤,៥៣% | ១៤,៤៨% | ១៧,៣៥% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤៣% | ៤,៤១% | ៤,៥៤% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៧៩% | ១១,៨០% | ១១,៨៥% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថាកសិករ | ១៨% | ១៨% | ៣១,២% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | ១៨% | ១៨% | ២៨,៨% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | ១៧,៦% | ១៨% | ២២,៨% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍

➡ក្នុងខែកក្កដាឆ្នាំ២០១៧ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៦៦,១ពាន់តោន កើនឡើង២១%ធៀបនឹងខែមុន និងកើនឡើង៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢រ៉ែ និងថាមពល:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៦៤៧,៩៧GWHមានការថយចុះ៤,៦% ធៀបនឹងខែមុន ប៉ុន្តែកើនឡើ១៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ២០១,៧៩ GWHមានការថយចុះ៤០% ធៀបនឹងខែមុន និងថយចុះ៤៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន៣១២,៧១GWHមានការកើនឡើង២៨%ធៀបនឹងខែមុន និងមានការកើនឡើង ១៨១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ឧស្សាហកម្ម:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៦៥៩,៨លានដុល្លារ មានការកើនឡើង៥% ធៀបនឹងខែមុន ប៉ុន្តែ ថយចុះ០,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន –កក្កដា ២០១៧ | ចំនួន– មិថុនា២០១៧ | ចំនួន–កក្កដា ២០១៦ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៩ | ៩ | ១២ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៦៣០ | ១៦២១ | ១៥៣០ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២៤ | ២២ | ១៣ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ២៨ | ៤១ | ៣០ |

➢សំណង់ (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៩២៩ពាន់ម²ថយចុះ៨%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៤៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង៣៦៤,១លានដុល្លារថយចុះ៣៧%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៣២%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម² –កក្កដា២០១៧ | ពាន់ម² –មិថុនា២០១៧ | ពាន់ម² –កក្កដា២០១៦ |
|---|---|---|---|
| ▪ លំនៅឋាន | ៤៣២,៧ | ៧៨៥,៨ | ៣៨៤,២ |
| ▪ ឧស្សាហកម្ម | ៣៥៨,៩ | ២១,៨ | ៦៣,២ |
| ▪ពាណិជ្ជកម្ម | ៧៧,១ | ១៤០,៥ | ១០១,៤ |
| ▪ ទេសចរណ៍ | ៥៥,៤ | ៥៩,៩ | ៦៨,៧ |
| ▪ផ្សេងៗ | ១,៨ | ០,៤ | ០,៧ |
| អនុញ្ញាតសរុប | ៩២៩ | ១០១៣,៨ | ៦៣៥,៧ |

✓ដូច្នេះ សំណង់អនុញ្ញាតដែលពេញនិយមនាខែនេះ គឺលំនៅដ្ឋាន៤៦,៥% និងឧស្សាហកម្ម៣៨,៦% នៃផ្ទៃក្រឡាសរុប។

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–កក្កដា ២០១៧ | នាក់–មិថុនា ២០១៧ | នាក់–កក្កដា ២០១៦ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបបនិងការងារ) | ១២៩៦ | ៦២០ | ១៦៧៣ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១៣៦១៦ | ១៣១៦០ | ១១៥៣២ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៨៩៨០ | ៩០០៦ | ៩១១៧ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៤៦៣៦ | ៤១៥៤ | ២៤១៥ |

## ➤វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | កក្កដា២០១៧ | មិថុនា២០១៧ | កក្កដា២០១៦ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ២៩៣៣ | ១៣៨៨ | ៨៥៨,៤ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ២០៦ | ៥៨ | ៦៧,៨ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ២០៩ (៧) | ១៦៧ (៥) | ៦៥,១ (២៥,៤) |
| វិស័យទេសចរណ៍ | ២៥១៩ | ៦៤៤ | ៦៧៩,៨ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ៥១៩ | ៤៥,៧ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ២៨ | ២៨ | ២០ |
| បង្កើតការងារ (ពាន់នាក់) | ៣៥ | ៥៤ | ១៥ |

➤**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន ៧២៩,៧ពាន់តោនថយចុះ១២%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៨%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៤.៥.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:+២០% | (+៣០%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:-៥៦% | (-៦៥%) |
| ▪ កំពង់ផែកំពង់សោម:-១៧% | (+១៧%) | ▪ កំពង់ផែឧកញ៉ាម៉ុង: -៥៨% | (-៦២%) |

## ➤ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៦,៦ | -៣% | +៦% |
| ក្នុងនោះទទួល | ២,៦ | +១៥% | +១២% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៩៦,៨ | +៤% | +១១% |
| ក្នុងនោះទទួល | ៥៤,២ | -៤% | +២២% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២៣៩០,២ | +៤% | -១៥% |
| ក្នុងនោះហៅចូល | ៦៩៨ | +៥% | -១៨% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ១១៤៧០,៣ | +១៥% | +១៧% |
| ក្នុងនោះហៅចូល | ១១៣៥៨,៩ | +១៥% | +១៧% |

## ➤ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៥ | ៣២% | ៤៤% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៤៩,២ | ៣០% | ៥៩% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៦១៤,៤ | ២០% | ២៨% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១៥៦,៧ | ១០,៤% | ៣៦% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៤៤៦,៦ | ១៨% | ១៣% |
| ✓ តាមផ្លូវអាកាស | ២៧០,៤ | ២១% | ២៧% |
| ✓ តាមផ្លូវគោក និងទឹក | ១៧៦,៣ | ១៤% | -៤% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនា ខែកក្កដាឆ្នាំ២០១៧ មានចំនួន៤៦៧១,៤ប៊ីលានរៀល (ស្មើនឹង១១៦៧លានដុល្លារ ស.រ.អា.) ថយចុះ០,៩% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៤,១% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ :

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +១,១% | +១៩,១% | រថយន្តសរុប (ប៊ី.ល.រ) | -៣០,៨% | +៤,៨% |
| ប្រេងម៉ាស៊ូត | +៨,៣% | +៨,១% | រថយន្តសរុប (គ្រឿង) | -៤% | -១,៦% |
| ឧស្ម័ន | +១៧,៨% | +៣៤,៤% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -៤២% | -៩% |
| អគ្គិសនីនាំចូល | +៣៣% | +៨១% | ម៉ូតូ (គ្រឿង) | -២៥,៥% | -១១,៣% |
| ដែកសំណង់ | +៣,១% | -៣១,៥% | អង្ករ | +១០០% | -៨៩,៤% |
| ស៊ីម៉ង់ត៍ | +១១,៧% | +២២,១% | ផ្លែឈើនិងបន្លែ | -១៧,៨% | +១១០,៣% |
| គ្រឿងអេឡិចត្រូនិក | +២២,១% | +៨០,៩% | ជីនិងថ្នាំកសិកម្ម | -២៦,៩% | -៧,៥% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -១២,៩% | -៣% |

➡ **ការនាំចេញ** ខែកក្កដា ឆ្នាំ២០១៧ មានចំនួន**៤៣៣៥,៣**ប៊ីលានរៀល ស្មើនឹង១០៨៣លានដុល្លារ ស.រ.អា. (៩២,៨% នៃការនាំចូល)ថយចុះ៧,១% ធៀបនឹងខែមុន និងថយចុះ៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| *ទំនិញ* | *%ធៀបនឹងខែមុន* | *%ធៀបនឹងខែដូចគ្នាឆ្នាំមុន* | *ទំនិញ* | *%ធៀបនឹងខែមុន* | *%ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|---|---|
| ផលិតផលឈើកែឆ្នៃ | -៤១,៦% | +២៥៦,៨% | ផលិតផលនេសាទ | -៦៥,៣% | -២៩% |
| វាយនភណ្ឌនិងស្បែកជើង | -៥,៣% | -៩,៣% | កៅស៊ូ | +២២,៣% | +២៨,៥% |
| អង្ករ | -២០,៧% | +៧,៩% | | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកក្កដា ឆ្នាំ២០១៧នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃប្រេងសាំង | ០,១% | ៦,៣% | |
| ២ | ថ្លៃប្រេងម៉ាស៊ូត | ០,៣% | ៦,៩% | — |
| ៣ | ចំណាយចរន្ត | ២៤,៥% | ៥៣,៧% | ជាពិសេសចំណាយជូនរដ្ឋបាលថ្នាក់មូលដ្ឋាន |

## ៧) សេចក្តីសន្និដ្ឋាន

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម:*

១) អត្រាអតិផរណាឆ្នាំ២០១៧នេះ រំពឹងថាមានកម្រិតទាប ប្រហែលជាជុំវិញ ៣,៥% ដែលក្នុងនោះ ខុសពីឆ្នាំមុនៗ ក្រុមម្ហូបអាហារពុំមានការឡើងថ្លៃខ្លាំងក្លាគួរឲ្យកត់សម្គាល់ទេ ប៉ុន្តែក្រុមឥន្ធនៈមាននិន្នាការឡើងថ្លៃវិញ។

២) កម្ពុជានាំចូលជ្រូកមិនតិចជាង ១៤០០ក្បាលក្នុងមួយថ្ងៃពីប្រទេសជិតខាង ដែលដាក់សម្ពាធលើវិស័យចិញ្ចឹមជ្រូកនៅកម្ពុជា។ ទន្ទឹមនឹងនោះ កសិករចិញ្ចឹមជ្រូកនៅកម្ពុជាក៏ប្រឈមនឹងបញ្ហាតម្លៃទាបពេកនៃជ្រូករស់ជាមួយនឹងគម្លាតយ៉ាងធំរវាងថ្លៃសាច់ជ្រូកនៅទីផ្សារ និងថ្លៃជ្រូករស់ដែលពួកគេលក់ (៧០០០ រៀល/គ.ក្រ ជ្រូករស់ទល់នឹង ២២៨០០ សាច់ជ្រូកសុទ្ធ។

៣) តួលេខទុនវិនិយោគអនុញ្ញាតដោយ ក.អ.ក. ក្នុងខែនេះមានការស្ទុះឡើងគួរឲ្យកត់សម្គាល់ (២៩៣៣ លានដុល្លារ) ដែលមួយភាគធំ ប្រហែល៨៦% ហូរទៅវិស័យទេសចរ ប៉ុន្តែវិស័យកសិកម្ម និងកសិឧស្សាហកម្មក៏មានចំណែកប្រហែល ៧%ដែរ ដែលពីមុនមកពុំសូវឃើញមានការវិនិយោគចូលក្នុងវិស័យនេះទេ៕

## IV- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា
## ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១៧

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៨/១៧<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ២ | ០១/០៨/១៧<br>ម៉ោង១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០២/០៨/១៧<br>ម៉ោង១៥:៣០នាទី | បន្តដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៣/០៨/១៧<br>ម៉ោង០៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយប្រតិភូកីឡាកម្ពុជា ចូលរួមការប្រកួតកីឡា SEA Games លើកទី២៩ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៥ | ០៣/០៨/១៧<br>ម៉ោង១៥:៣០នាទី | ចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| | | ២-សេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ០៤/០៨/១៧<br>**ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។<br>៣-បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ "ពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ និងកិច្ចព្រមព្រៀងមួយចំនួនទៀត ក្រោមកិច្ចព្រមព្រៀងក្របខណ្ឌនេះ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) និងសាធារណរដ្ឋប្រជាមានិតចិន"។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៧ | ០៥/០៨/១៧<br>**ម៉ោង០៨:០០នាទី** | ចូលរួមកិច្ចប្រជុំដកពិសោធន៍អំពីចំណុចខ្លាំង និងចំណុចខ្វះខាតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤ កន្លងមក និងវិធានការគន្លឹះសំខាន់ៗដើម្បីទទួលបានជោគជ័យក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ឃឹន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ៨ | ១០/០៨/១៧<br>**ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការសម្របសម្រួល និងសហការជាមួយភាគីចិន លើគម្រោងសាងសង់អគារសន្តិសុខនៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សាការងារសាងសង់អគារសន្តិសុខនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាមួយនឹងការិយាល័យសេដ្ឋកិច្ច និងពាណិជ្ជកម្មនៃស្ថានទូតសាធារណរដ្ឋប្រជាមានិតចិនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនសាជីវកម្មផ្លូវដែកចិនលេខ១១(China Railway 11th Bureru Group Corporation Ltd) ក្រោមជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១០/០៨/១៧<br>**ម៉ោង១៥:៣០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **យូឃាង ថាវរិទ្ធ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
| --- | --- | --- |
| ១០ | **១១/០៨/១៧ ម៉ោង០៨:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាស និងផ្ទេរភារកិច្ចថ្នាក់ដឹកនាំរាជបណ្ឌិត្យសភាកម្ពុជា និងប្រកាសគោរមងារបណ្ឌិតសភាចារ្យ និងសមាសភាពថ្នាក់ដឹកនាំ នៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១១ | **១១/០៨/១៧ ម៉ោង១៥:៣០នាទី** | ចូលរួមកិច្ចប្រជុំពិភាក្សាអំពីគោលការណ៍រៀបចំធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារថ្នាក់កណ្តាល និងថ្នាក់ជាតិចុះជួយមូលដ្ឋានស្រុក ក្រុង ឃុំ សង្កាត់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ចិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | **១៤/០៨/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ១៣ | **១៨/០៨/១៧ ម៉ោង០៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយប្រតិភូកីឡាប៉ារ៉ាឡាំពិកកម្ពុជា ទៅចូលរួមការប្រកួតកីឡាជនពិការអាស៊ាន លើកទី៩ នៅទីក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី និងជូនរង្វាន់កីឡាករជ័យលាភីមេដាយមាស ក្នុងការប្រកួតកីឡាប៉ារ៉ាឡាំពិកយុវជន ជនពិការរដូវក្តៅ នៅសាធារណរដ្ឋកូរ៉េ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៤ | **២០/០៨/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីជួបសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសាលមហោស្រពកោះពេជ្រ។ |
| ១៥ | **២២/០៨/១៧ ម៉ោង០៨:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងវេទិកាថ្នាក់ជាតិលើកទី២ស្តីពី "ការការពារ និងអភិរក្សធនធានធម្មជាតិ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៦ | **២២/០៨/១៧ ម៉ោង១៥:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើៈ<br>១-សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០។<br>៣-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៨-២០២០។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៧ | **២៣/០៨/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីជួបសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ខណ្ឌពោធិ៍សែនជ័យ។ |
| ១៨ | **២៣/០៨/១៧ ម៉ោង១៥:៣០នាទី** | បន្តដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០។<br>៣-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៨-២០២០។<br>៤-បញ្ហាផ្សេងៗ។ ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | **២៤/០៨/១៧ ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សាលើការត្រៀមរៀបចំកិច្ចប្រជុំគណៈរដ្ឋមន្ត្រីចម្រុះកម្ពុជា-ថៃលើកទី៣ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២០ | **២៤/០៨/១៧ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែកក្កដា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២១ | **២៥/០៨/១៧ ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០។<br>៣-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៨-២០២០។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២២ | **២៧/០៨/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីជួបសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសាលមហោស្រពកោះពេជ្រ។ |
| ២៣ | **២៩/០៨/១៧ ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៤ | **២៩/០៨/១៧ ម៉ោង១៥:៣០នាទី** | ចូលរួមក្នុងកិច្ចប្រជុំដើម្បីពិភាក្សាលើសេចក្តីព្រាងរបាយការណ៍បូកសរុបអំពីលទ្ធផលធំៗ នៃការអនុ-វត្តកម្មវិធីនយោបាយរបស់គណបក្សពីឆ្នាំ២០១៣-២០១៧ និងគោលនយោបាយសំខាន់ៗពីឆ្នាំ២០១៨-២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការគណបក្សទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in